## វិធីសាស្ត្របុរាណសម្រាប់ដោះស្រាយបញ្ហាសត្វល្អិតនាពេលបច្ចុប្បន្ន

កសិករ ប្រើប្រាស់សត្វអង្ក្រង *(Oecophylla smaragdina, Hymenoptera)* សម្រាប់ការពារដំណាំស្វាយ និងក្រូច ពីសត្វល្អិតបំផ្លាញ នៅតំបន់អាស៊ីអស់រយៈពេលជាង 2000 ឆ្នាំ មកហើយ ដូច្នេះ វាគឺជាការអនុវត្តការការពារដំណាំបែបធម្មជាតិដ៏យូរមកហើយក្នុងវិស័យកសិកម្ម។ ប៉ុន្តែមានកសិករខ្នាតតូចមួយចំនួនប៉ុណ្ណោះនៅតាមដងទន្លេមេគង្គបន្តរក្សាសត្វអង្ក្រងដែលជាសត្វល្អិតមានប្រយោជន៍ដើម្បីកាត់បន្ថយការបំផ្លាញនៃសត្វល្អិតជាពិសេសលើដំណាំស្វាយចន្ទី។

តាមធម្មតា កសិករតែងឃើញមានសត្វអង្ក្រងរស់នៅក្នុងចម្ការស្វាយចន្ទីសរីរាង្គ ប៉ុន្តែពួកគាត់ភាគច្រើនមិនបានដឹងនៅឡើយពីអត្ថប្រយោជន៍ដ៏ច្រើន ក៏ដូចជាវិធីសាស្ត្រដើម្បីរក្សា និងបង្កើនចំនួនរបស់វាដើម្បីប្រើវាការពារដំណាំពីសត្វល្អិតបំផ្លាញ។

ឯកសារណែនាំបច្ចេកទេសរៀបចំដោយ៖ Rada Kong, Mathilde Sester, Sievmeng Ly, Phal Sophat, Jean-Philippe Deguine





## បទពិសោធន៍របស់កសិករ



អ្នកស្រី **សេង សុវណ្ណារីម** ជាកសិករដាំស្វាយចន្ទី និងបានចូលរួមជាមួយគម្រោង ASSET នៅខេត្តព្រះវិហារ

### តើអ្នកស្រីបានរៀនអំពីសត្វអង្ក្រងដោយរបៀបណា?

ពេលប្រមូលផលគ្រាប់ស្វាយចន្ទី សត្វអង្ក្រងបានខាំខ្ញុំ និងឪពុកខ្ញុំ ដូច្នេះឪពុកខ្ញុំចង់បាញ់ថ្នាំសម្លាប់វា។ ប៉ុន្តែខ្ញុំបានជំទាស់ ហើយបង្ហាញគាត់ថា តាមពិតសត្វអង្ក្រងមានអត្ថប្រយោជន៍ដោយសារវាសំលាប់ និងស៊ីដង្កូវ (កង្កូវមូលស្លឹក កង្កូវស៊ីញៀ កង្កូវចោះផ្លែ)។ ខ្ញុំប្រាប់គាត់ឱ្យសង្កេតមើលដើម និងមែកដែលមានសត្វអង្ក្រង មានផ្លែច្រើន ហើយគាត់ជឿខ្ញុំថា ការរក្សាសត្វអង្ក្រងជួយកំចាត់សត្វល្អិត។

### តើអ្នកស្រីបានពង្រីកចំនួនអង្ក្រងទៅគ្រប់ដើមទាំងអស់ក្នុងចម្ការឬទេ?

ខ្ញុំបានរៀនពីរបៀបផ្ទេរសំបុកអង្ក្រងពីគម្រោង ប៉ុន្តែគ្រួសាររបស់ខ្ញុំមិនមានពេលគ្រប់គ្រាន់ទេ។ ខ្ញុំមិនបានផ្ទេរសំបុកទេ ប៉ុន្តែខ្ញុំឈប់ឲ្យអ្នកចាក់អង្ក្រង (ចាក់សំបុកយកពង និងកូនទៅលក់នៅផ្សារ) ក្នុងចម្ការរបស់ខ្ញុំ។ សូម្បីប្តីខ្ញុំក៏ចង់យកធ្វើជាចំណីត្រីក្នុងស្រះក៏ខ្ញុំប្រាប់គាត់ថាកុំ។ ដូច្នេះខ្ញុំសង្កេតឃើញសត្វអង្ក្រងមានស្ទើរគ្រប់ដើមក្នុងចម្ការរបស់ខ្ញុំ។

### តើគុណភាពនៃគ្រាប់ចន្ទីយ៉ាងម៉េចដែរ? តើវាមានគុណភាពល្អជាងឬទេ?

គ្រាប់ចន្ទីធំស្មើ ស្អាត និងរលោងល្អជាង។ ទោះទុកយូរក៏សាច់វានៅស និងពេញល្អ។ ខ្ញុំសាកកាប់១០គ្រាប់មើល។ ខ្ញុំឃើញថា ៩ គ្រាប់ មានសាច់ពេញ។ ខ្ញុំមិនដឹងពីរសជាតិយ៉ាងម៉េចទេ ប៉ុន្តែខ្ញុំជឿថារសជាតិវាក៏ល្អជាងដែរ។

ដាំដុះមាននិរន្តរភាព បរិភោគដើម្បីសុខភាព

**អនុវត្តកសិអេកូឡូស៊ី**

@ASSETProjectSEA

សហការផលិត៖ HEKS EPER, Agroecology and Safe Food System Transitions

សម្របសម្រួល៖ GRET, cirad

ជំនួយហិរញ្ញវត្ថុ៖ AFD, Co-funded by the European Union, Fonds Français pour l'Environnement Mondial

This document has been produced with the financial assistance of the French Development Agency (AFD), the European Union (EU) and the French Facility for Global Environment (FFEM). The views expressed herein can in no way be taken to reflect the official opinion of the AFD, EU and FFEM.



ឯកសារណែនាំបច្ចេកទេស៖

# សត្វអង្ក្រង៖ ការអនុវត្តអេកូឡូស៊ីបែបធម្មជាតិដើម្បីការពារសត្វបំផ្លាញលើចម្ការស្វាយចន្ទី



## តើធ្វើដូចម្តេចដើម្បីពង្រីក និងរក្សាចំនួនសត្វអង្រ្កង?

ដើម្បីពង្រីក និងធានាអោយមានវត្តមានសត្វអង្រ្កងជាអចិន្ត្រៃយ៍ក្នុងចម្ការស្វាយចន្ទី កសិករគួរអនុវត្តន៍តាមការណែនាំដែលមានពាជំហានសំខាន់ៗ។ កសិករគួរអនុវត្តនៅខែវិច្ឆិកា ព្រោះជាពេលចេញត្រួយ ផ្កា និងក្តិប ទាក់ទាញសត្វល្អិតបំផ្លាញ ដែលជាចំណីសត្វអង្រ្កង។ ពេលសំបូរចំណី សត្វអង្រ្កងចាប់ផ្តើមបង្កើតសំបុកថ្មីៗ ពង្រីកចំនួនឆាប់រហ័ស និងរស់នៅក្នុងចម្ការចន្ទីតែម្តង។

### ជំហានទី 1៖ កំណត់វត្តមាន និងគ្រួសារអង្រ្កង

- កំណត់ដើមដែលមានសត្វអង្រ្កងដោយយកឈើគោះដើម ឬមែកស្រាលៗ។
- កំណត់គ្រួសារសត្វអង្រ្កងដោយយកអង្រ្កងពីដើម១ ទៅជួបនៅដើម១ទៀត។ បើវាខាំគ្នា វានៅក្នុងគ្រួសារផ្សេងគ្នា ហើយបើមិនខាំគ្នាទេ មានន័យថាវានៅក្នុងគ្រួសារតែមួយ។
- គូសផែនទីចំការ សម្គាល់ដើមណាមានសត្វអង្រ្កង និងស្ថិតក្នុងគ្រួសារមួយណា ហើយតំណត់ដើមសម្រាប់ពង្រីក។




### ជំហានទី 2៖ ពង្រីកចំនួនអង្រ្កង

- ពិនិត្យដើមចន្ទីអំណោយផលសម្រាប់ការផ្ទេរសំបុក៖ ត្រូវមានមែកច្រើន ស្លឹកខ្ចីៗ និងគ្មានស្រមោចខ្មៅដែលកសិករហៅថាត្រោក។ ត្រូវកម្ចាត់ត្រោកដោយកាត់សំបុកយកចោល និងសំលាប់ចំនួនដែលនៅសល់ ព្រោះអង្រ្កងខ្លាចត្រោក។



- ការផ្ទេរសំបុកសត្វអង្រ្កងទៅចម្ការដែលគ្មានសត្វអង្រ្កង៖
  - ជ្រើសយកសំបុកធំ និងថ្មីពីចំការផ្សេង ឬព្រៃក្បែរនោះ។ កាត់សំបុកដាក់ក្នុងការុងរួចចងមាត់ ហើយយកទៅចងព្យួរនៅដើមដែលចង់ផ្ទេរ ដោយស្រាយចំហរមាត់ការុង។ រក្សាទុកការុងរយៈពេល 2-3 ថ្ងៃ អោយអង្រ្កងវារចេញបង្កើតសំបុក និងជញ្ជូនពង និងកូនមិនទាន់ញាស់ទៅរស់នៅសំបុកថ្មី។



- ការពង្រីកចំនួនសត្វអង្រ្កងក្នុងចម្ការ៖
  - ប្រើខ្សែចងភ្ជាប់មែកដើមដែលមានសត្វអង្រ្កងទៅដើមដែលគ្មាន ដើម្បីសម្រួលអោយសត្វអង្រ្កងផ្លាស់ទី និងអាចបង្កើតសំបុករស់នៅនៅដើមថ្មីៗ។
  - ដើម្បីពង្រីកចំនួនអោយបានច្រើនក្នុងរយៈពេលខ្លី កសិករអាចផ្ទេរសំបុកសត្វអង្រ្កងដូចបានពិពណ៌នាខាងលើ។

**ស្កែន ឬចុចលើតំណភ្ជាប់**
ដើម្បីមើលវីដេអូបច្ចេកទេស


សហការផលិតដោយ
HEKS EPER Bread for all
Agroecology and Safe Food System Transitions




### ជំហានទី 3៖ ការពារ និងថែរក្សាចំនួនសត្វអង្រ្កង

- ជៀសវាងការប្រើប្រាស់ថ្នាំសំលាប់សត្វល្អិត និងថ្នាំសំលាប់ស្មៅ ព្រោះវាអាចសម្លាប់ ឬប្រដេញសត្វអង្រ្កងបាន។
- រក្សា ឬដាំដើមឈើដូចជា ស្វាយ ក្រូចឆ្មា ឬ ដើមឈើហូបផ្លែផ្សេងទៀតនៅជុំវិញ ឬក្នុងចំការ។ ដើមឈើទាំងនេះផ្តល់ជម្រក និងប្រភពអាហារសម្រាប់សត្វអង្រ្កង ជាពិសេសនៅរដូវវស្សា ពេលដើមចន្ទីជ្រុះស្លឹក និងមិនសំបូរចំណី។
- តាមដានដើមចន្ទីដែលមានគ្រួសារសត្វអង្រ្កងផ្សេងគ្នា។ បើមែកវាប៉ះគ្នា កសិករត្រូវកាត់មែកចោលដើម្បីការពារកុំអោយវាខាំគ្នា។
- ចៀសវាងការចាក់សំបុកសត្វអង្រ្កងប្រមូលយកពង និងកូន ព្រោះធ្វើអោយថយចំនួនសត្វអង្រ្កង។

## តើសត្វអង្រ្កងអាចការពារដើមឈើហូបផ្លែយ៉ាងដូចម្តេច?

ក្នុងកំឡុងពេល ចេញត្រួយ ចេញផ្កា និងបង្កើតក្តិប គឺជាពេលដែលដើមចន្ទីងាយទទួលការបំផ្លាញពីសត្វល្អិត។ វាក៏ជាពេលដែលត្រួយ ផ្កា និងក្តិបទាំងនេះបញ្ចេញទឹកដម ហើយសត្វអង្រ្កងប្រមូលយកទឹកដមទាំងនេះទៅទុកក្នុងសំបុកធ្វើចំណី។ សត្វអង្រ្កងធ្វើចលនាទៅគ្រប់ទីកន្លែងដើម្បីប្រមូលយកទឹកដមនេះ ហើយវាក៏ត្បាតការពារដើមចន្ទីពីសត្វល្អិតបំផ្លាញដោយវាសំលាប់ធ្វើជាចំណី ឬប្រដេញ។ ជាធម្មតាសត្វអង្រ្កងធ្វើចលនារាល់ 30-60 វិនាទី ដូច្នេះវាមានប្រសិទ្ធភាពខ្ពស់ក្នុងការការពារសត្វល្អិតបំផ្លាញលើដើមចន្ទី។

